# STUDENTNET(**បណ្តាញសិស្ស**)**និង គម្រោងការសិក្សាសម្រាប់សិស្សម្នាក់ៗ** (ILP) **ព័ត៌មានពិតៗ**

## តើ StudentNet (បណ្តាញសិស្សជាអ្វី)?

StudentNet គឺជាកម្មវិធីប្រើកុំព្យូទ័ររបស់ក្រសួងអប់រំ សម្រាប់សិស្សពិនិត្យមើលឯកសារសិក្សារបស់ពួកគេ ដើម្បីមើលព័ត៌មានសំខាន់ៗ សម្រាប់ធ្វើគម្រោងការទៅកាន់ការបញ្ចប់ការសិក្សារបស់ពួកគេ និងអ្វីៗលើសពីនេះទៀត។ គោលបំណងគឺធ្វើឲ្យសិស្សយល់ពីព័ត៌មាន និង ធនធាន ដែលពួកគេត្រូវការដើម្បីទទួលបានជោគជ័យ។ StudentNet មានសម្រាប់សិស្សានុសិស្ស**ទាំងអស់** ពីថ្នាក់មត្តេយ្យ ដល់ថ្នាក់ទី១២ ដែលបានចុះឈ្មោះរៀននៅក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា។ សិស្សានុសិស្សដែលបានចេញពីសាលា ឬឈប់មករៀន អាចប្រើ StudentNet បាន នៅពេលដែលគេចុះឈ្មោះចូលរៀននៅក្រសួងអប់រំវិញ។

StudentNet (បណ្តាញសិស្ស) ផ្តល់ឲ្យសិស្សានុសិស្សនូវអ្វីៗដូចតទៅ៖

- ឯកសារសិក្សា៖ ចំណាត់ថ្នាក់ ពិន្ទុដែលរៀនបាន វត្តមានអវត្តមាន មធ្យមភាគនៃពិន្ទុ និងពិន្ទុបានពីការប្រឡង standardized test ពីឆ្នាំសិក្សា២០០១-២០០២ រហូតដល់បច្ចុប្បន្ន
- គម្រោងការសិក្សាសម្រាប់សិស្សម្នាក់ៗ៖ (សូមមើលនៅខាងក្រោម)
- សៀវភៅអាន៖ សៀវភៅអានសម្រាប់កម្មវិធីសិក្សាសំខាន់ៗរបស់ក្រសួងអប់រំស្ទើរតែទាំងអស់ មាននៅក្នុងអ៊ិនធ័រណិត
- ប្រអប់សម្រាប់វិធីសាស្ត្រនៃការសិសក្សា (Learning Toolbox)៖ វីដេអូជំនួយនៃការបង្ហាត់បង្រៀន ការណែនាំពីការត្រៀមខ្លួនប្រឡង PSSA ព័ត៌មានសម្រាប់រាវរកក្នុងអ៊ិនធ័រណិត និងអ្វីៗជាច្រើនទៀត។
- ព័ត៌មាន និងជំនួយផ្សេងៗ៖ ព័ត៌មានអំពីការជ្រើសរើសវិទ្យាល័យ គម្រោងការសម្រាប់ អាជីព/មហាវិទ្យាល័យ ការងារ ការរៀនធ្វើការ កម្មវិធីក្រោយម៉ោងសិក្សា និងនៅរដូវក្តៅ វិធីផ្សេងទៀតទៅកាន់ការបញ្ចប់ការសិក្សា សេវាគាំទ្រសង្គម និងអ្វីៗជាច្រើនទៀត។

## តើគម្រោងការសិក្សាសម្រាប់សិស្សម្នាក់ៗ (ILP) ជាអ្វី?

គម្រោងការសិក្សាសម្រាប់សិស្សម្នាក់ៗគឺជា ឯកសារផ្ទាល់ខ្លួនដែលសិស្សបង្កើតឡើងជាមួយអ្នកផ្តល់ឱវាទរបស់ពួកគេ និងអ្នកដែលជួយគាំទ្រដ៏ទៃទៀត ដើម្បីបង្កើតនូវទិសដៅ សម្រាប់ផ្លូវទៅកាន់ជោគជ័យក្នុងជីវិត ក្រោយពេលបញ្ចប់ការសិក្សា រៀបគម្រោងផែនការពីការរីកចម្រើន ដើម្បីសម្រេចតាមគោលបំណងទាំងនោះ ក្នុងកំឡុងឆ្នាំសិក្សានីមួយៗ និងដើម្បីសម្រេចថាតើធនធាន ឬជំនួយអ្វីដែលពួកគេត្រូវការ ដើម្បីជួយឲ្យបានសម្រេចដល់ទិសដៅទាំងនោះ។ សិស្សានុសិស្ស អាចរកមើល និងបន្ថែមបន្ថយ គម្រោងការសិក្សាសម្រាប់សិស្សម្នាក់ៗរបស់ខ្លួន នៅពេលណាក៏បាន ដោយចុចចូលក្នុងអ៊ិនធ័រណិត តាមរយៈឈ្មោះ និងលេខ សម្ងាត់របស់ខ្លួន នៅក្នុង StudentNet ។

StudentNet និងគម្រោងការសិក្សាសម្រាប់សិស្សម្នាក់ៗ ទាំងពីរនេះ មានសម្រាប់សិស្សក្រសួងអប់រំទាំងអស់ ពីថ្នាក់មត្តេយ្យ ដល់ថ្នាក់ទី១២។ សម្រាប់ឆ្នាំសិក្សា ២០០១០-១១ គឺតម្រូវឲ្យ អ្នកផ្តល់ឱវាទ និងបុគ្គលិកសាលាផ្សេងទៀត ធ្វើការជាមួយសិស្សថ្នាក់ទី៩ ដល់ ទី១២ ទាំងអស់ ដើម្បីបង្កើតគម្រោងការសិក្សាសម្រាប់សិស្សម្នាក់ៗ ហើយត្រូវប្រើ StudentNet នេះឲ្យបានទៀតទាត់។

## តើសិស្សានុសិស្សអាចប្រើ StudentNet និងគម្រោងការសិក្សាសម្រាប់សិស្សម្នាក់ៗ ដោយរបៀបណា?

សិស្សានុសិស្សត្រូវការ អត្តលេខសិស្ស និង ពាក្យសម្ងាត់ របស់ពួកគេ ទើបអាចប្រើ StudentNet បាន។ អ្នកផ្តល់ឱវាទផ្តល់ឲ្យសិស្សនូវ ពាក្យសម្ងាត់សម្រាប់ StudentNet ។ សិស្សអាចចុចចូល StudentNet តាមរយ: www.philasd.org ដោយចុចលើពាក្យ "Login" ដែលនៅផ្នែកខាងលើនៃទំព័រ រួចហើយសរសេរអត្តលេខសិស្ស និងពាក្យសម្ងាត់របស់ខ្លួន នៅក្នុងប្រអប់ពណ៌ខៀវរបស់ "សិស្ស"។ សិស្សថ្នាក់វិទ្យាល័យណាដែលប្រើ StudentNet ជាលើកដំបូង ត្រូវចុចត្រង់ពាក្យ "Register for an Account" រួចហើយត្រូវធ្វើតាមការបង្គាប់ប្រាប់ជាបន្តបន្ទាប់។

នៅពេលដែលអ្នកចូលក្នុង StudentNet នឹងមានប្រអប់ចុចនៅលើគេហទំព័រ សម្រាប់មើល ILP របស់ខ្លួន។

## តើមាតាបិតាអាចប្រើបានដែរឬទេ?

មាតាបិតា និងអាណាព្យាបាលអាចមើលឯកសារពិន្ទុ និង ILP របស់កូនខ្លួន នៅក្នុង FamilyNet (បណ្តាញគ្រួសារ)។ ដើម្បីចុះឈ្មោះយក ឈ្មោះអ្នកប្រើ ក្នុង FamilyNet មាតាបិតា/អាណាព្យាបាល ត្រូវមានថ្ងៃខែកំណើត និងអត្តលេខសិស្ស របស់កូនខ្លួន។ ដើម្បីជ្រាបព័ត៌មានបន្ថែមអំពីវិធីចុះឈ្មោះ ឬ ពីការប្រើ FamilyNet សូមចូលទៅ www.philasd.org រួចហើយចុចត្រង់ពាក្យ "FamilyNet" នៅក្នុងប្រអប់ពណ៌បៃតងរបស់ "មាតាបិតា"។

## តើត្រូវទៅកន្លែងណា ដើម្បីរកជំនួយ និង រៀនបន្ថែមទៀត?

- សម្រាប់ពាក្យសម្ងាត់ និង ជំនួយផ្សេងៗ សិស្សគប្បីទាក់ទងជាមួយអ្នកផ្តល់ឱវាទរបស់ខ្លួន
- សម្រាប់បញ្ហាខាងបច្ចេកទេស បុគ្គលិករបស់សាលាគប្បីទាក់ទងទៅ Help Desk៖ ២១៥-៤០០-៥៥៥៥ ឬ helpdesk@philasd.org
- សម្រាប់ព័ត៌មាន និង ជំនួយបន្ថែម ពី StudentNet និង ILP សូមមើលក្នុង៖ www.philasd.org/offices/studentnet